**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ :...១០៣.សសរ

ថ្ងៃពុធ ០៥រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២១

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារតាមដាន បូកសរុបអំពីសភាពការណ៍ជាតិ និងអន្តរជាតិ លទ្ធផលការងាររបស់ក្រសួងមហាផ្ទៃ និងសុន្ទរកថារបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃ សមាជិក-សមាជិការាជរដ្ឋាភិបាលកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹតលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ស ម្រេ ច

**ប្រការ ១ ._**

ត្រូវបានបង្កើតក្រុមការងារតាមដាន បូកសរុបអំពីសភាពការណ៍ជាតិ និងអន្តរជាតិ លទ្ធផលការងាររបស់ក្រសួងមហាផ្ទៃ និងសុន្ទរកថារបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃសមាជិក-សមាជិការាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តម **ថាច់ ទណ្ឌះ** អគ្គលេខាធិការរង នៃអគ្គលេខាធិកាដ្ឋាន *ប្រធាន*

២. ឯកឧត្តម **ម៉ែន ម៉ុនរិទ្ធ** អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល *អនុប្រធាន*

៣. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ផាត សុផានិត** អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ *អនុប្រធាន*

៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហោ សំរាត** អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋាន ព័ត៌មានវិទ្យា *អនុប្រធាន*

៥. លោក **ម៉ា សំណាង** ប្រធាននាយកដ្ឋានសរុប និងស្ថិតិ *សមាជិកអចិន្ត្រៃយ៍*

៦. លោក ឧត្តមសេនីយ៍ទោ **អ៊ុំ ចាសនា** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា *សមាជិក*

៧. លោក **ហ៊ឹម មាតុគូមិ** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល *សមាជិក*

៨. លោក **ឌី សុផល** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល *សមាជិក*

៩. លោក **ណាង មុនីវង្ស** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ *សមាជិក*

១០. លោក **សុខ សុផានី** អនុប្រធាននាយកដ្ឋានសរុប និងស្ថិតិ *សមាជិក*

**ប្រការ ២ .** _

ក្រុមការងារនេះមានភារកិច្ច ៖

- តាមដាន បូកសរុប អំពីសភាពការណ៍អន្តរជាតិ និងសភាពការណ៍អន្តរជាតិពាក់ព័ន្ធនឹងកម្ពុជា
- រៀបចំ បូកសរុប អំពីខ្លឹមសារសំខាន់ៗ នៃសុន្ទរកថារបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី
- រៀបចំ បូកសរុប លទ្ធផលការងាររបស់ក្រសួងមហាផ្ទៃ
- បូកសរុប រៀបចំរបាយការណ៍ប្រចាំខែគោរពជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដើម្បីពិនិត្យ និងសុំអនុសាសន៍ដឹកនាំជំខ្ពង់ខ្ពស់
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៣ .** _

ក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជួយការងារតាមតម្រូវការចាំបាច់។

**ប្រការ ៤.** _

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

***កន្លែងទទួល:***

- រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទទួលបន្ទុក (ដើម្បីជូនជ្រាប)
- ដូចប្រការ៤ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ